ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាអាជ្ញាកណ្តាល**

**THE ARBITRATION COUNCIL**

លេខ និង ឈ្មោះសំណុំរឿង ៖ ០០២/១៩ - ប្រេស្ទីច ហ្គាម៉ិន ឯ.ក

កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ គល់ វឌ្ឍនា

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ អន ណន

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ ប៉ែន ប៊ុនឈា

## ភាគីនៃវិវាទ

**១- ភាគីនិយោជក**

ឈ្មោះ ៖ **ក្រុមហ៊ុន ប្រេស្ទីច ហ្គាម៉ិន ឯ.ក**

អាសយដ្ឋាន ៖ ភូមិក្រាំងតាំ ឃុំត្បែង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល

ទូរស័ព្ទ ៖ ០៦៩ ៨៣៣ ៨៣៣/០៩៦ ៨៨៧ ៨៨៨៧ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមសវនាការលើកទី១ ៖

១- លោក ឈួន តារា — មេធាវី

តំណាងភាគីនិយោជកចូលរួមសវនាការលើកទី២ ៖

១- លោក ឈួន តារា — មេធាវី

២- លោក Ko Cheng Shen — ប្រធានរដ្ឋបាល

៣- លោក សៅ សុគន្ធា — ប្រធានផ្នែកធនធានមនុស្ស

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖ **ភាគីតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងារនៅក្រុមហ៊ុន ប្រេស្ទីច ហ្គាម៉ិន ឯ.ក**

អាសយដ្ឋាន ៖ ភូមិក្រាំងតាំ ឃុំត្បែង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល

ទូរស័ព្ទ ៖ ០៨៧ ៧៩៧ ៨៦៦/០៦៩ ២៣៣ ៤២៤ ទូរសារ ៖ គ្មាន

តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការលើកទី១ ៖

| | |
|---|---|
| ១- លោក ទូន សារ៉េន | អគ្គលេខាធិការសម្ព័ន្ធសហជីពចលនាកម្មករ |
| ២- លោក ព្រាប មុន្នីសុវណ្ណ | មន្ត្រីសម្ព័ន្ធសហជីពចលនាកម្មករ |
| ៣- លោក សុខ វណ្ណា | មន្ត្រីសម្ព័ន្ធសហជីពចលនាកម្មករ |
| ៤- លោក ហួន សុរិត | ប្រធានសហជីពចលនាកម្មករមូលដ្ឋាន |
| ៥- លោក ភួង វីរៈ | អនុប្រធានសហជីពចលនាកម្មករមូលដ្ឋាន |
| ៦- លោក មុត ធារ៉ាន់ | លេខា |
| ៧- លោក សាន សារីម | លេខារង |
| ៨- លោក សុខ ទិន | គណកម្មការ |
| ៩- លោកស្រី មាន ចាន្នី | កម្មករ |
| ១០- លោកស្រី ឃឹម ស្រីណេង | កម្មករ |
| ១១- លោកស្រី អឿន សំបូ | កម្មករ |
| ១២- កញ្ញា ជា មុំ | កម្មករ |

តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការលើកទី២ ៖

| | |
|---|---|
| ១- លោក ទូន សារ៉េន | អគ្គលេខាធិការសម្ព័ន្ធសហជីពចលនាកម្មករ |
| ២- លោក ព្រាប មុន្នីសុវណ្ណ | មន្ត្រីសម្ព័ន្ធសហជីពចលនាកម្មករ |
| ៣- លោក សុខ វណ្ណា | មន្ត្រីសម្ព័ន្ធសហជីពចលនាកម្មករ |
| ៤- លោក ហួន សុរិត | ប្រធានសហជីពចលនាកម្មករមូលដ្ឋាន |
| ៥- លោក សាន សារីម | លេខារង |
| ៦- លោក មុត ធារ៉ាន់ | លេខា |
| ៧- លោក សុខ ទិន | គណកម្មការ |
| ៨- លោកស្រី មាន ចាន្នី | កម្មករ |
| ៩- លោកស្រី អឿន សំបូ | កម្មករ |
| ១០- លោកស្រី ឃឹម ស្រីណេង | កម្មករ |
| ១១- កញ្ញា ជា មុំ | កម្មករ |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- សូមឱ្យក្រុមហ៊ុនទទួលយក លោក ហួន សុវិត ប្រធានសហជីពចលនាកម្មករប្រចាំរោងចក្រ ប្រេស្ទីច ហ្គាមិន ឯ.ក ចូលធ្វើការងារវិញ។ ក្រុមហ៊ុនមិនបន្តកិច្ចសន្យាការងារជូនលោក ហួន សុវិត ទេ។

២- ក្រុមហ៊ុនមិនត្រូវកាត់លុយកម្មករ នៅពេលកម្មករដាក់ច្បាប់កន្លះថ្ងៃ ក្រុមហ៊ុនមិនត្រូវកាត់លុយបាយ។ ក្រុមហ៊ុនកាត់តាមថ្ងៃដែលកម្មករបានឈប់ នៅពេលកម្មករមានច្បាប់ ឬសុំច្បាប់ត្រឹមត្រូវ។

៣- នៅពេលកម្មករ-កម្មការិនីដាក់ច្បាប់មានធុរៈចាំបាច់ ក្រុមហ៊ុនត្រូវអនុញ្ញាត និងរក្សាប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗនៅដដែល ជូនពួកគាត់។ ក្រុមហ៊ុនផ្តល់ច្បាប់ជូន ឯប្រាក់ឈ្នួល និងអត្ថប្រយោជន៍អនុវត្តតាមច្បាប់។

៤- សូមឱ្យក្រុមហ៊ុនប្តូរកិច្ចសន្យា ពី ២ ខែ មក ៦ ខែ វិញម្តង។ ក្រុមហ៊ុនអនុវត្តកិច្ចសន្យាការងារមានថិរវេលាកំណត់ (០៣ ខែ)។

៥- សុំឱ្យក្រុមហ៊ុនដករដ្ឋបាលចេញពីការងារជាបន្ទាន់។ នេះជាការសម្រេចចិត្តរបស់ភាគីក្រុមហ៊ុន។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ២២០ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ (អាណត្តិទី១៦)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ប្រេស្ទីច ហ្គាមិន ឯ.ក លេខ ១៤៣/១៩ ក.ប/កណ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៩ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៩។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖**

- លើកទី១ ៖ ថ្ងៃព្រហស្បតិ៍ ១២កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩ វេលាម៉ោង ១៤ និង ០០ នាទីរសៀល។

- លើកទី២ ៖ ថ្ងៃអង្គារ ២រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ត្រូវនឹងថ្ងៃទី២២ ខែមករា ឆ្នាំ២០១៩ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក។

**បញ្ហានីតិវិធី៖**

នៅថ្ងៃទី០២ ខែមករា ឆ្នាំ២០១៩ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានទទួលពាក្យបណ្តឹងពីកម្មករនិយោជិត នៃក្រុមហ៊ុន ប្រេស៊ីច ហ្គាម៉ិន ស្តីពីការទាមទារលក្ខខណ្ឌការងារ ចំនួន ១៤ ចំណុច ឱ្យល្អប្រសើរ។ បន្ទាប់ពីទទួលពាក្យបណ្តឹងនេះមក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយវិវាទការងារនេះ តាមនីតិវិធីច្បាប់ ដោយបានធ្វើការផ្សះផ្សានៅថ្ងៃទី០២ ខែមករា ឆ្នាំ២០១៩ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នា ចំនួន ៥ ចំណុច។ ចំណុចមិនសះជាដែលនៅសល់ចំនួន ៥ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៩ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ប្រេស៊ីច ហ្គាម៉ិន ឯ.ក លេខ ១៤៣/១៩ ក.ប/កណចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៩។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើង នៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានទទួលលិខិតមួយច្បាប់ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៩ របស់ក្រុមហ៊ុន ប្រេស៊ីច ហ្គាម៉ិន ដែលមានកម្មវត្ថុ ៖ សំណើសុំចេញសេចក្តីបញ្ជាដើម្បីផ្អាកការធ្វើកូដកម្មរបស់កម្មករនិយោជិតនៅក្រុមហ៊ុន ប្រេស៊ីច។ ហេតុនេះ នៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានចេញសេចក្តីបញ្ជា លេខ ០០២/១៩ កបអ. ឱ្យផ្អាកជាបន្ទាន់នូវការធ្វើកូដកម្មរបស់កម្មករនិយោជិតនៃក្រុមហ៊ុន ប្រេស៊ីច ហ្គាម៉ិន ឯ.ក រហូតដល់នីតិវិធីនៃអាជ្ញាកណ្តាលត្រូវបានបញ្ចប់សព្វគ្រប់តាមនីតិវិធីច្បាប់ ហើយកូដករទាំងអស់ត្រូវត្រឡប់ចូលធ្វើការវិញ ចាប់ពីព្រឹកថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៩ តទៅ តាមវេនរបស់ខ្លួន។ ករណីនេះ ភាគីកម្មករនិយោជិតបានចូលធ្វើការវិញ តាមវេនរៀងខ្លួន តាមសេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ហេតុនេះ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិត មកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជា ចំនួន ៥ ចំណុចនេះ នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។ ករណីនេះ ភាគីនិយោជកបានស្នើសុំលើកពេលសវនាការ ដោយមូលហេតុ តំណាងភាគីនិយោជកដែលជាមេធាវី ទើបតែទទួលបានលិខិតពីងពាក់ និងផ្ទេរសិទ្ធិ ហេតុនេះ គាត់មិនអាចមានពេលរៀបចំសំណុំរឿងទាន់ពេល។ ម្យ៉ាងវិញទៀត ភាគីកម្មករនិយោជិតក៏មិនជំទាស់នឹងការស្នើសុំនេះ ហេតុនេះ ក្រុមប្រឹក្សា-អាជ្ញាកណ្តាលសម្រេចលើកពេលសវនាការ មកថ្ងៃទី២២ ខែមករា ឆ្នាំ២០១៩ វេលាម៉ោង ៨ និង ៣០ នាទី ព្រឹកវិញ។ ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទដើម្បីផ្សះផ្សានៅសល់នេះ និងបានធ្វើការផ្សះផ្សាបន្ថែមទៀត ដោយទទួលបានលទ្ធផលសះជានឹងគ្នា ចំនួន ៤ ចំណុច ដោយភាគីទាំងពីរបានព្រមព្រៀងគ្នាលើចំណុចវិវាទទី២, ទី៣, ទី៤ និងទី៥ ដោយឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលសរសេរជាស្មារតី

នៅក្នុងសេចក្តីបង្គាប់នេះតែម្តង។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាចំណុចមិនសះជា ចំនួន ១ ចំណុច តែប៉ុណ្ណោះ គឺចំណុចវិវាទទី១។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ជាថ្ងៃផុតកំណត់ផ្តល់ឯកសារ និងថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៩ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារ។

ភាគីទាំងពីរបានឯកភាពពន្យារកាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល ពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៩ ទៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩ វិញ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិតចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៩ របស់ក្រុមហ៊ុន ប្រេស្ទីច ហ្គាម៉ិន គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំចេញសេចក្តីបញ្ជា ដើម្បីផ្អាកការធ្វើកូដកម្មរបស់កម្មករនិយោជិត នៅក្រុមហ៊ុន ប្រេស្ទីច ហ្គាម៉ិន។

២- ពាក្យសុំពន្យាពេលសវនាការរបស់មេធាវី ឈួន តារា ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩ គោរពជូន ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល។

៣- លិខិតតំណាងដោយអាណត្តិរបស់មេធាវី ឈួន តារា ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩ គោរពជូន ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល។

៤- លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិរបស់អាណត្តិទាយក Li Min ប្រគល់សិទ្ធិជូន លោកមេធាវី ឈួន តារា ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩។

៥- លិខិតប្រគល់-ទទួលសិទ្ធរបស់លោកស្រី ចាង លុ យ៉ានមុី ជាប្រធានក្រុមហ៊ុន Prestige Garment Co., Ltd តែងតាំង និងប្រគល់ភារកិច្ចជូន អ្នកស្រី Li Min។

៦- សារណាសង្ខេបនៃវិវាទការងាររបស់មេធាវី ឈួន តារា គោរពជូន ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៩។

៧- ប័ណ្ណពន្ធប៉ាតង់ឆ្នាំ២០១៨ លេខ PTL២០១៨១១៩៧៦ អពដ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៨។

ARBITRATION COUNCIL

៨- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុន ប្រេស៊ីច ហ្គាម៉ិន ឯ.ក លេខ MOC-១២១៤០៧១៩ ពណ.ចបព ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៨។

៩- លក្ខន្តិកៈក្រុមហ៊ុន ប្រេស៊ីច ហ្គាម៉ិន ឯ.ក ចុះទិដ្ឋាការលេខ ១៩៧០/១៨ ពណ ចបព ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨។

១០- ប័ណ្ណជូនដំណឹងការបញ្ចប់កិច្ចសន្យា/ការមិនបន្តកិច្ចសន្យា គោរពជូន លោក ហួន សុរិត ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨។

១១- បញ្ជីឈ្មោះបុគ្គលិកដែលដល់កុងត្រាសម្រាប់ខែ១២។

១២- ប្រវត្តិរូបសង្ខេបរបស់ ហួន សុរិត ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៨។

១៣- តារាងកំណត់ហេតុសំរាប់ធ្វើតេស្តរបស់ ហួន សុរិត ចូលម្រើការងារថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៨។

១៤- ពាក្យសុំចូលបម្រើការងាររបស់ ហួន សុរិត ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៨។

១៥- អត្តសញ្ញាណប័ណសញ្ជាតិខ្មែររបស់ ហួន សុរិត។

១៦- កិច្ចសន្យាក្នុងការសាកល្បងរបស់ ហួន សុរិត ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៨។

១៧- កពន្យាកិច្ចសន្យា ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៨។

១៨- កិច្ចសន្យាការងាររបស់ ហួន សុរិត ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៨។

១៩- របាយការណ៍បង្រៀនដល់កម្មករ កម្មការិនី មុនចូលបម្រើការងារ របស់ ហួន សុរិត។

២០- សំនួរសម្រាប់ធ្វើការសំភាសកម្មករ កម្មការិនី។

២១- លិខិតព្រមាន ហួន សុរិត ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨។

២២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមក្រុមហ៊ុន ប្រេស៊ីច ហ្គាម៉ិន ឯ.ក ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៩។

២៣- ឯកសារជារូបភាព។

២៤- ពាក្យសុំបញ្ចូលភស្តុតាងរបស់មេធាវី ឈួន តារា ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៩។

២៥- លិខិតរបស់ប្រធានក្រុមរបស់លោក ហ៊ួន សុរិត បញ្ជាក់ថា អាកប្បកិរិយា...។

២៦- លិខិតវាយតម្លៃស្នាដៃរបស់ កម្មករនិយោជិត ហួន សុរិត ក្នុងខែឧសភា ខែមិថុនា និងខែកក្កដា។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- បង្កាន់ដៃទទួលពាក្យស្នើសុំចុះបញ្ជីសហជីពចលនាកម្មករនៃរោងចក្រ ប្រេស៊ីច ហ្គាម៉ិន លេខ ០០៨៧ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨។

២- លិខិតរបស់ប្រធានសហជីពចលនាកម្មករប្រចាំរោងចក្រកាត់ដេរ ប្រេស៊ីច ហ្គាម៉ិន គោរពជូន ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល ស្តីពីជូនដំណឹងស្តីពីសមាសភាពថ្នាក់ដឹកនាំ

សហជីព និងសមាជិកគណៈកម្មាធិការសហជីពចលនាកម្មករប្រចាំរោងចក្រកាត់ដេរ ប្រេស្ទីច ហ្គាម៉ិន ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

៣- លិខិតប្តឹងជំទាស់ឯកសាររបស់ភាគីនិយោជក ដែលដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៩។

៤- លិខិតរបស់ប្រធានក្រុមរបស់លោក ហ៊ួន សុរិត បញ្ជាក់ថា អាកប្បកិរិយា...។

៥- លិខិតវាយតម្លៃស្នាដៃរបស់ កម្មករនិយោជិត ហួន សុរិត ក្នុងខែឧសភា ខែមិថុនា និងខែកក្កដា។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ប្រេស្ទីច ហ្គាម៉ិន ឯ.ក លេខ ១៤៣/១៩ ក.ប/កណ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៩។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ប្រេស្ទីច ហ្គាម៉ិន ឯ.ក ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៩។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ប្រេស្ទីច ហ្គាម៉ិន ឯ.ក លេខ ០០១/១៩ កប/កណ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៩ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- សេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០០២/១៩ កបអ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩។

២- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ០២៨ កប/អក/វក/លកអ. ចុះថ្ងៃព្រហស្បតិ៍ ៥កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩។

៣- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ០២៩ កប/អក/វក/លកអ. ចុះថ្ងៃព្រហស្បតិ៍ ៥កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩។

៤- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ០៤៣ កប/អក/វក/លកអ. ចុះថ្ងៃព្រហស្បតិ៍ ១២កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩។

៥- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ០៤៤ កប/អក/វក/លកអ. ចុះថ្ងៃព្រហស្បតិ៍ ១២កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩។

THE ARBITRATION COUNCIL

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖**

- ក្រុមហ៊ុន ប្រេស្ទីច ហ្គាម៉ិន ឯ.ក គឺជាក្រុមហ៊ុនដែលមានសកម្មភាពចម្បងកាត់ដេរសម្លៀកបំពាក់ និងបានទទួលវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ ០០០៣៤៩៦៩ ចុះថ្ងៃទី១ ខែសីហា ឆ្នាំ២០១៨។ បច្ចុប្បន្នក្រុមហ៊ុននេះជួលកម្មករនិយោជិតសរុប ចំនួន ៤៤៣ នាក់ *(យោងតាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ប្រេស្ទីច ហ្គាម៉ិន ឯ.ក)*
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានចេញលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោ-ជិត ក្នុងការដោះស្រាយវិវាទការងាររួម លេខ ០០១/១៩ ក.ប/កណ ចុះថ្ងៃទី៣ ខែមករា ឆ្នាំ២០១៩ ដែលមានកម្មករនិយោជិត ចំនួន ៦ នាក់ គឺ ១. ហួន សុវិត, ២. ឃឹម ស្រីណេង, ៣. សាន សារឹម, ៤. ជឿន ស្រីភ័ស្ត, ៥. មាន ចន្ធី និង៦. អឿន សំបូរ ជាអ្នកតំណាងភាគីកម្មករនិយោជិតនៃក្រុមហ៊ុន ប្រេស្ទីច ហ្គាម៉ិន ឯ.ក ក្នុងការដោះស្រាយវិវាទការងាររួម។
- នៅថ្ងៃសវនាការក្រុមប្រឹក្សាអាជ្ញាកណ្តាល គឺមានវត្តមានរបស់កម្មករនិយោជិតដែលជាអ្នកតំណាងភាគីកម្មករនិយោជិត ចំនួន ៥ នាក់ មានឈ្មោះ ១. ហួន សុវិត, ២. ឃឹម ស្រីណេង, ៣. សាន សារឹម, ៤. មាន ចន្ធី និង៥. អឿន សំបូ ដែលមានឈ្មោះនៅក្នុងលិខិតបញ្ជាក់អ្នកតំណាងខាងលើ។
- មិនមានអង្គហេតុណាមួយបញ្ជាក់ថា នៅក្នុងក្រុមហ៊ុននេះ មានសហជីពដែលមានភាពជាតំណាងបំផុតទេ។

**ចំណុចវិវាទទី ១ ៖ *ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកទទួលយក ហួន សុវីត ប្រធានសហជីពចលនាកម្មករ ប្រចាំរោងចក្រ ប្រេស្ទីច ហ្គាលម៉ិន ឯ.ក ចូលធ្វើការវិញ***

- ភាគីទាំងពីរឯកភាពថា ៖
    - កម្មករនិយោជិត ហួន សុវីត ចូលធ្វើការនៅដំបូងនៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៨ ជាកម្មករនិយោជិតផ្នែកដេរ ដោយមានកិច្ចសន្យាសាកល្បងការងារ ចំនួន ១ ខែ និងបន្ទាប់មក ប្រើកិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ចំនួន ៣ ខែម្តងៗ។ កិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ៣ ខែ ចុងក្រោយ គឺចាប់ពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៨ រហូតដល់ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨។
    - និយោជកបានជូនដំណឹងស្តីពីការមិនបន្តកិច្ចសន្យាការងាររបស់កម្មករនិយោជិត ~~ហួន សុវីត~~ នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៨។
    - និយោជកបានបញ្ចប់កិច្ចសន្យាការងាររបស់កម្មករនិយោជិតនៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៨ ពោលគឺមុនពេលកិច្ចសន្យាការងាររបស់គាត់ដល់កាលកំណត់។ តែយ៉ាងណាមិញ និយោជកបានគិតប្រាក់

ឈ្នួលជូនគាត់ រហូតដល់ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨ ដែលជាថ្ងៃផុតរលត់នៃកិច្ចសន្យាការងាររបស់គាត់។

- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារឱ្យនិយោជកទទួលយកកម្មករនិយោជិត ហួន សុវីត ចូលធ្វើការវិញ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារ ដូចខាងក្រោម ៖
  - កម្មករនិយោជិត ហួន សុវីត គឺជាបេក្ខជនដែលជាប់ឆ្នោតជាថ្នាក់ដឹកនាំសហជីព ហេតុនេះគាត់ទទួលបានការការពារពិសេសពីការបញ្ឈប់ពីការងារ។ តាំងពីពេលបង្កើតសហជីពរួចមក និយោជកបានតាមដាន និងចាប់កំហុសគាត់រហូត ហើយនិយោជកបានលើកឡើងទៀតថា ប្រសិនបើចង់ឱ្យនិយោជកបន្តកិច្ចសន្យាការងារជូនគាត់ គាត់ត្រូវតែលាលែងចេញពីសហជីពនេះ។
  - ម្យ៉ាងទៀត កម្មករនិយោជិត ហួន សុវីត គឺមិនបានប្រព្រឹត្តកំហុសអ្វីនោះទេ។ គាត់គឺជាកម្មករនិយោជិតល្អ ដែលធ្វើការលឿនជាងកម្មករនិយោជិតដទៃទៀតក្នុងក្រុម។
  - និយោជកមានការរើសអើងសហជីព ដោយនិយោជកបានបញ្ឈប់លេខាធិការសហជីព និងបានបញ្ឈប់កម្មករនិយោជិត ១១ នាក់ ផ្សេងទៀត ដែលបានចូលរួមធ្វើកូដកម្មផងដែរ។
- ភាគីនិយោជកបានបញ្ជាក់ថា និយោជកមិនអាចទទួលយកកម្មករនិយោជិត ហួន សុវីត ឱ្យចូលធ្វើការវិញនោះទេ ដោយមូលហេតុថា ៖
  - ករណីនេះ គឺជាការមិនបន្តកិច្ចសន្យាការងារដែលមានកំណត់ថិរវេលារបស់កម្មករនិយោជិត ហួន សុវីត។ និយោជកបានជូនដំណឹងស្តីពីការមិនបន្តកិច្ចសន្យាការងារនេះរួចហើយ ជាងនេះទៀត ការដែលនិយោជកបញ្ឈប់គាត់ មុនពេលដែលកិច្ចសន្យាការងាររបស់គាត់ដល់ការផុតរលត់ ដោយមូលហេតុថា និយោជកមិនចង់ឱ្យមានបញ្ហានៅថ្ងៃចុងក្រោយរបស់គាត់។ ករណីនេះ និយោជកក៏បានគិតប្រាក់ឈ្នួលជូនគាត់ រហូតដល់ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨ ដែលជាថ្ងៃផុតរលត់នៃកិច្ចសន្យាការងារដែរ។
  - និយោជកមិនបន្តកិច្ចសន្យាការងាររបស់កម្មករនិយោជិត ហួន សុវីត ដោយមូលហេតុថា គាត់មិនស្តាប់តាមការចាត់ចែងរបស់ប្រធាន, ដេរយឺត, ធ្លាប់មានការព្រមានទាក់ទងនឹងការដេរបាត់ផ្លាកអាវ និងមានការវាយតម្លៃពីប្រធានផ្នែករៀងរាល់ខែ។
  - និយោជកមិនបានដឹងអំពីសមាសភាពរបស់គាត់ដែលជាថ្នាក់ដឹកនាំសហជីពនោះទេ។
- ភាគីកម្មករនិយោជិតបានបដិសេធនឹងការលើកឡើងរបស់និយោជកខាងលើ ដោយអះអាងថា ៖
  - កម្មករនិយោជិត ហួន សុវីត គឺជាកម្មករនិយោជិតដែលតែងតែស្តាប់តាមការចាត់ចែងរបស់ប្រធានក្រុមជានិច្ច។ ហើយក៏ជាកម្មករកនិយោជិតដែលដេរលឿនជាងកម្មករនិយោជិតដទៃទៀតផងនិងមានពេលខ្លះទៀត ប្រធានតែងតែចាត់ចែងឱ្យគាត់ទៅជួយដេរកម្មករនិយោជិតផ្សេងទៀតផងដែរ។

THE ARBITRATION COUNCIL

- ចំពោះការបាត់ផ្លាកនេះ គឺជាការព្រមានដោយភាន់ច្រលំតែប៉ុណ្ណោះ ប៉ុន្តែក្រោយមកទៀត ទើបនិយោជកដឹងថា ករណីនេះ កម្មករនិយោជិត ហួន សុវីត មិនបានដេរបាត់ផ្លាកនោះទេ ដោយមូលហេតុថា លេខារបស់ប្រធានក្រុម បើកអាវជូនកម្មករនិយោជិត ហួន សុវីត លើសកំណត់ ដែលជាហេតុធ្វើឱ្យមានការខ្វះផ្លាក។ និយោជកក៏មានលើកឡើងថា និយោជកនឹងលុបចោលការព្រមាននោះពីកម្មករនិយោជិត ហួន សុវីត ហើយទៅព្រមានលេខារបស់ប្រធានក្រុមវិញ ប៉ុន្តែជាក់ស្តែង និយោជកមិនបានលុបចោលការព្រមាននោះទេ ហើយថែមទាំងយកមកដាក់កំហុសលើរូបគាត់ទៀត។

- ព័ត៌មានពាក់ព័ន្ធនឹងការបង្កើតសហជីព ៖
  - ភាគីកម្មករនិយោជិតបានលើកឡើងថា សហជីពចលនាកម្មករប្រចាំរោងចក្រកាត់ដេរ ប្រេស៊ីច ហ្គាមេន គឺបានរៀបចំការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីព នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៨ ដោយមានបេក្ខជនជាប់ឆ្នោតជាថ្នាក់ដឹកនាំសហជីព ចំនួន ៣ នាក់ និងរួមទាំងកម្មករនិយោជិតជាសមាជិក ដែលមានសរុបចំនួន ១១ នាក់ ក្នុងនោះរួមមានឈ្មោះ ហួន សុវីត ជាប់ជាប្រធានសហជីពផងដែរ។ *(យោងតាមលិខិតរបស់កម្មករនិយោជិតដែលមានកម្មវត្ថុ ៖ ជូនដំណឹងអំពីសមាសភាពថ្នាក់ដឹកនាំ និងសមាជិកគណៈកម្មាធិការសហជីពចលនាកម្មករប្រចាំរោងចក្រកាត់ដេរ ប្រេស៊ីច ហ្គាមេន ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៨)*
  - នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៨ ភាគីកម្មករនិយោជិតបានយកលិខិតជូនដំណឹងអំពីសមាសភាពថ្នាក់ដឹកនាំ និងសមាជិកគណៈកម្មាធិការសហជីពចលនាកម្មករប្រចាំរោងចក្រកាត់ដេរ ប្រេស៊ីច ហ្គាមេន ទៅឱ្យឈ្មោះ សៅ សុគន្ធា ប៉ុន្តែ គាត់បដិសេធមិនទទួលយកលិខិតជូនដំណឹងរបស់សហជីពឡើយ។ ហើយនៅពេលដែលកម្មករនិយោជិតយកលិខិតទៅជូនរដ្ឋបាលនោះ គឺមានវត្តមានរបស់លោក កូ ឆេងសិន ដែលជាប្រធានរដ្ឋបាល (ដែលបានចូលរួមក្នុងសវនាការអាជ្ញាកណ្តាលនេះដែរ)។ ករណីនេះ នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា តំណាងភាគីនិយោជក ដែលមានឈ្មោះ កូ ឆេងសិន ដែលជាប្រធានរដ្ឋបាល ដែលបានចូលរួមក្នុងសវនការអាជ្ញាកណ្តាលនេះដែរ ក៏ទទួលស្គាល់ដែរថា កម្មករនិយោជិត ហួន សុវីត បានយកលិខិតទៅឱ្យឈ្មោះ សៅ សុគន្ធា ប៉ុន្តែ គាត់មិនបានដឹងថា លិខិតនោះជាលិខិតអ្វីនោះទេ។
  - នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨ ភាគីកម្មករនិយោជិតដាក់លិខិតជូនដំណឹងអំពីសមាសភាពថ្នាក់ដឹកនាំ និងសមាជិកគណៈកម្មាធិការសហជីពចលនាកម្មករប្រចាំរោងចក្រ ប្រេស៊ីច ហ្គាមេន ទៅប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល ដោយមានបង្កាន់ដៃលេខាទទួលពីឈ្មោះ ជឹម ចំណាន ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨។

- ០ នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨ ភាគីកម្មករនិយោជិតបានដាក់ពាក្យសុំចុះបញ្ជីការសហជីព ទៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល (យោងតាមបង្កាន់ដៃទទួលពាក្យស្នើសុំចុះបញ្ជីរបស់មន្ទីរការងារ ខេត្តកណ្តាល ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨)។

- ករណីនេះ ភាគីនិយោជកបានដាក់ឯកសារជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ដូចខាងក្រោម ៖
  - ០ កិច្ចសន្យាការងាររបស់កម្មករនិយោជិត ហួន សុវីត មានកិច្ចសន្យាសាកល្បងការងារ និងកិច្ចសន្យាការងារដែលមានរយៈពេល ៣ ខែម្តងៗ។
  - ០ ប័ណ្ណជូនដំណឹងការបញ្ចប់កិច្ចសន្យា/ការមិនបន្តកិច្ចសន្យា របស់កម្មករនិយោជិត ហួន សុវីត ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨។
  - ០ បញ្ជីឈ្មោះបុគ្គលិកដែលដល់កុងត្រាសម្រាប់ខែ១២ មានកម្មករនិយោជិតសរុប ចំនួន ១២ នាក់ ក្នុងនោះ គឺនិយោជកបានបន្តកិច្ចសន្យាការងារជូនទាំងអស់ លើកលែងតែកម្មករនិយោជិត ហួន សុវីត ដែលនិយោជកមិនបន្តកិច្ចសន្យាការងារ។
  - ០ ប្រវត្តិរូបសង្ខេប, តារាងកំណត់ហេតុសម្រាប់ធ្វើតេស្ត, ពាក្យសុំបម្រើការងារ និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ របស់កម្មករនិយោជិត ហួន សុវីត។
  - ០ លិខិតព្រមាន ចំពោះកម្មករនិយោជិត ហួន សុវីត ចំពោះការដើរបាត់ផ្លូក ដោយមានហត្ថលេខាទទួលស្គាល់ដោយកម្មករនិយោជិត។

**ចំណុចវិវាទទី ២ ៖ *ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកមិនត្រូវកាត់លុយកម្មករនៅពេលកម្មករដាក់ច្បាប់កន្លះថ្ងៃ និយោជកមិនត្រូវកាត់លុយបាយ***

- នៅថ្ងៃសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភាគីទាំងពីរឯកភាពគ្នាថា ៖ ភាគីនិយោជកឯកភាពកាត់ប្រាក់ថ្លៃបាយថ្ងៃត្រង់ ចំនួន ២០០០ រៀល តាមចំនួន ថ្ងៃដែលកម្មករនិយោជិតឈប់សម្រាកមានធុរៈផ្សេងៗ ដោយមានច្បាប់អនុញ្ញាតត្រឹមត្រូវពីនិយោជក។ ករណីកម្មករនិយោជិតឈប់សម្រាកដោយពុំមានច្បាប់អនុញ្ញាតទេ ក្រុមហ៊ុនកាត់ប្រាក់បាយថ្ងៃត្រង់កន្លះខែ។

**ចំណុចវិវាទទី ៣ ៖ *ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជក នៅពេលកម្មករ-កម្មការិនី ដាក់ច្បាប់មានធុរៈចាំបាច់ ក្រុមហ៊ុនត្រូវអនុញ្ញាត និងរក្សាប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ នៅដដែលជូនពួកគាត់***

- នៅថ្ងៃសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភាគីទាំងពីរឯកភាពគ្នាថា ៖ ភាគីនិយោជកឯកភាពកាត់ប្រាក់ឈ្នួលប្រចាំថ្ងៃ និងអត្ថប្រយោជន៍ផ្សេងៗតាមសមាមាត្រនៅពេលកម្មករនិយោជិតឈប់សម្រាកមានធុរៈផ្សេងៗ ដោយមានច្បាប់អនុញ្ញាតត្រឹមត្រូវពីក្រុមហ៊ុន។

**ចំណុចវិវាទទី ៤ ៖ *ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកប្តូរកិច្ចសន្យា ពី ២ ខែ មក ៦ ខែ ម្តង***

- នៅថ្ងៃសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភាគីទាំងពីរឯកភាពគ្នាថា ៖ ភាគីនិយោជក និងកម្មករនិយោជិតឯកភាពអនុវត្តកិច្ចសន្យាការងារស្របតាមច្បាប់ស្តីពីការងារ និងផលប្រយោជន៍ភាគី...

**ចំណុចវិវាទទី ៥ ៖ *ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកដកអ្នករដ្ឋបាលចេញពីការងារជាបន្ទាន់***

- នៅថ្ងៃសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភាគីទាំងពីរឯកភាពគ្នាថា ៖ ភាគីនិយោជកឯកភាពឱ្យលោកស្រី អ៊ុក សោភ័ណ្ឌ ជាអ្នកចាត់ការទូទៅ ត្រូវមានអាកប្បកិរិយា និងប្រើពាក្យសម្តីឱ្យបានសមរម្យមកលើកម្មករនិយោជិត។

**ហេតុផលនៃសេចក្តីសម្រេច ÷**

មុននឹងពិចារណាលើចំណុចទាមទារខាងក្រោមនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាអំពីដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ ដូចខាងក្រោម ៖

កថាខណ្ឌទី១ នៃមាត្រា ៥៤ នៃច្បាប់ស្តីពីសហជីព ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ចែងថា ៖ *"ភាពជាតំណាងបំផុតនៃសហជីពត្រូវបានទទួលស្គាល់នៅក្នុងក្របខ័ណ្ឌនៃសហគ្រាស ឬគ្រឹះស្ថាន។ សម្រាប់គោលបំណងនៃការចរចាអនុសញ្ញារួម ឬដោះស្រាយវិវាទការងាររួម គឺសហជីពដែលមានភាពជាតំណាងបំផុតទទួលបានសិទ្ធិផ្តាច់មុខ។"* ។

យោងតាមខ្លឹមសារនៃកថាខណ្ឌទី១ នៃមាត្រា ៥៤ នៃច្បាប់ស្តីពីសហជីពខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ថា មានតែសហជីពដែលមានភាពជាតំណាងបំផុតប៉ុណ្ណោះ ដែលមានសិទ្ធិផ្តាច់មុខនៅក្នុងការចរចាបង្កើតអនុសញ្ញារួម និងដោះស្រាយវិវាទការងាររួមនៅក្នុងសហគ្រាស ឬគ្រឹះស្ថានរបស់ខ្លួន។ សិទ្ធិផ្តាច់មុខក្នុងការដោះស្រាយវិវាទការងាររួមនេះ សំដៅលើសិទ្ធិក្នុងការនាំយកវិវាទ និងធ្វើជាតំណាងឱ្យកម្មករនិយោជិតនៅគ្រប់នីតិវិធីដោះស្រាយវិវាទការងាររួម ដោយរួមបញ្ចូលទាំងនីតិវិធីដោះស្រាយវិវាទនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលផងដែរ។ *(សូមមើលបន្ថែមសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ១៨០/១៦-ស៊ីម៉ង់ត៍ កម្ពុជា ចក្រីទីង និងលេខ ១៧១/១៦-ដេវើលីន ខូអិលធីឌី)*

យោងតាមអង្គហេតុបញ្ជាក់ថា នៅក្នុងក្រុមហ៊ុននេះមិនទាន់មានសហជីពដែលមានភាពជាតំណាងបំផុតទេ។

ប្រការ ១៦ នៃប្រកាសលេខ ៣០៣ ក.ប/ប្រ.ក.គ.ប.ក ស្តីពីភាពជាតំណាងបំផុតនៃសហជីព និងបែបបទ និងនីតិវិធីដើម្បីទទួលបានភាពជាតំណាងបំផុត ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៨ ចែងថា ៖ *"ក្នុងករណីសហគ្រាស គ្រឹះស្ថានដែលពុំទាន់មានសហជីព ឬពុំទាន់មានសហជីពដែលមានភាពជាតំណាងបំផុត ការដោះស្រាយវិវាទការងាររួម ត្រូវដោះស្រាយដោយអ្នកតំណាងកម្មករនិយោជិត។"* ។

លើសពីនេះ ប្រការ១ នៃប្រកាសលេខ ៣៦២ ក.ប/ប្រ.ក ស្តីពីការធ្វើប្រតិភូកម្មមុខងារក្នុងការធ្វើបណ្តឹងអំពីវិវាទការងាររួម និងចេញលិខិតទទួលស្គាល់ប្រតិភូក្រុមប្រឹក្សាចរចា ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចែងថា ៖ *"ត្រូវបានធ្វើប្រតិភូកម្មជូនដល់ប្រធាននាយកដ្ឋានវិវាទការងារ និងប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត នូវមុខងារ ដូចខាងក្រោម ៖*

*...*

*- ចេញលិខិតទទួលស្គាល់ប្រតិភូក្រុមប្រឹក្សាចរចា សម្រាប់ដោះស្រាយវិវាទការងាររួម។"*

ARBITRATION COUNCIL

យោងតាមប្រការ១ នៃប្រកាសលេខ ៣៦២ ក.ប/ប្រ.ក ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ថា នាយកដ្ឋានវិវាទការងារ និងប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត មានមុខងារក្នុងការទទួលស្គាល់ កម្មករនិយោជិត ឱ្យធ្វើជាតំណាងរបស់ភាគីកម្មករនិយោជិត ដើម្បីដោះស្រាយវិវាទការងាររួម។ ដូច្នេះ កម្មករ និយោជិតដែលត្រូវបានទទួលស្គាល់ដោយនាយកដ្ឋានវិវាទការងារ ឬប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត មានសិទ្ធិស្របច្បាប់ក្នុងការតំណាងឱ្យភាគីកម្មករនិយោជិត ដើម្បីដោះស្រាយវិវាទការងាររួម ដោយរួមទាំងនៅ ដំណាក់កាលដោះស្រាយវិវាទការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលផងដែរ នៅពេលមិនទាន់មានវត្តមានរបស់សហជីព មានភាពតំណាងបំផុត។ (*សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ២២៧/១៦-យូនីកតា ថេកណឡជី (ខេមបូឌា), លេខ ២២៨/១៦-កាស៊ីណូកោះមាស និង សណ្ឋាគារ, លេខ ០០៨/១៧-ថបវើលដ៍ ហ្គាមិន (ខេមបូឌា) អិលធីឌី និង លេខ ២៣៧/១៦-ហ្សិណា-ដាយដុង (ខេមបូឌា) អេឡិចត្រូនិច)* ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របទៅនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញា-កណ្តាលនៅក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

ក្នុងសំណុំរឿងនេះ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល បានចេញលិខិតបញ្ជាក់ អ្នកតំណាង ភាគីកម្មករនិយោជិត ក្នុងការដោះស្រាយវិវាទការងាររួម លេខ ០០១/១៩ ក.ប/កណ ចុះថ្ងៃទី៣ ខែមករា ឆ្នាំ ២០១៩ ដែលមានកម្មករនិយោជិត ចំនួន ៦ នាក់ គឺ ១. ហួន សុរិត, ២. ឃឹម ស្រីណេង, ៣. សាន សារីម, ៤. ជឿន ស្រីភ័ស្ត, ៥. មាន ចន្ទី និង៦. អឿន សំបូរ ជាអ្នកតំណាងភាគីកម្មករនិយោជិតនៃក្រុមហ៊ុន ប្រេស៊ីច ហ្គាម៉ិន ឯ.ក ក្នុងការដោះស្រាយវិវាទការងាររួម។ នៅថ្ងៃសវនាការក្រុមប្រឹក្សាអាជ្ញាកណ្តាល គឺមានវត្តមានរបស់កម្មករនិយោជិត ដែលជាអ្នកតំណាងភាគីកម្មករនិយោជិត ចំនួន ៥ នាក់ មានឈ្មោះ ១. ហួន សុរិត, ២. ឃឹម ស្រីណេង, ៣. សាន សារីម, ៤. មាន ចន្ទី និង៥. អឿន សំបូ ដែលមានឈ្មោះនៅក្នុងលិខិតបញ្ជាក់អ្នកតំណាងខាងលើ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិតចំនួន ៥ នាក់ ខាងលើ មានសិទ្ធិធ្វើជា តំណាងកម្មករនិយោជិត នៃក្រុមហ៊ុន ប្រេស៊ីច ហ្គាម៉ិន ក្នុងការដោះស្រាយវិវាទការងាររួមនៅក្រុមប្រឹក្សាអាជ្ញា-កណ្តាល ស្របតាមប្រការ១ នៃប្រកាសលេខ ៣៦២ ក.ប/ប្រ.ក ខាងលើ។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាចំណុចវិវាទនៅក្នុងសំណុំរឿងនេះ សម្រាប់កម្មករនិយោជិត នៅក្នុងក្រុមហ៊ុន ប្រេស៊ីច ហ្គាម៉ិន ដែលជាដើមបណ្តឹង។

**ចំណុចវិវាទទី ១ ៖ *ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកទទួលយកកម្មករនិយោជិត ហួន សុរីត ចូលធ្វើការវិញ***

យោងតាមអង្គហេតុ កម្មករនិយោជិត ហួន សុរីត គឺមានកិច្ចសន្យាការងារមានកំណត់ថិរវេលា ដែលកិច្ចសន្យា ការងារ ៣ ខែ ចុងក្រោយ របស់គាត់ ត្រូវដល់ការផុតរលត់នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨។ ករណីនេះ និយោជក បានជូនដំណឹងស្តីពីការមិនបន្តកិច្ចសន្យាការងាររបស់គាត់ នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៨។ និយោជកបានបញ្ចប់ កិច្ចសន្យាការងាររបស់កម្មករនិយោជិត ហួន សុរីត នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៨ ដែលត្រូវនឹងថ្ងៃសៅរ៍ តែយ៉ាងណាមិញ និយោជកបានគិតប្រាក់ឈ្នួលជូនកម្មករនិយោជិត ហួន សុរីត រហូតដល់ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨ ដែលជា ថ្ងៃផុតរលត់នៃកិច្ចសន្យាការងាររបស់គាត់។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើការដែលនិយោជកបញ្ចប់កិច្ចសន្យាការងាររបស់កម្មករនិយោជិត ហួន សុវីត ជាការបញ្ឈប់ ឬជាការមិនបន្តកិច្ចសន្យាការងារដែលមានកំណត់ថិរវេលា?

កថាខណ្ឌទី១ មាត្រា ៧៣ នៃច្បាប់ស្តីពីការងារ ចែងថា ៖ *"កិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ត្រូវផុតរលត់តាមធម្មតានៅពេលដល់កាលកំណត់ ។..."* ។

នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយថា ការផុតរលត់នៃកិច្ចសន្យាការងារដែលមានកំណត់ថិរវេលាធ្វើឱ្យទំនាក់ទំនងការងាររវាងកម្មករនិយោជិត និងនិយោជក ត្រូវផុតរលត់ដោយស្វ័យប្រវត្តិ ហើយការសម្រេចចិត្តបន្តកិច្ចសន្យាសារជាថ្មីទៀត ឬ មិនបន្តនោះ ជាសិទ្ធិរបស់ភាគីនៃកិច្ចសន្យា ព្រោះកិច្ចសន្យា គឺជាការព្រមព្រៀងរវាងភាគី ដែលមិនមានភាគីណាមួយអាចបង្ខំភាគីមួយទៀតឱ្យបន្តកិច្ចសន្យាទេ ប្រសិនបើគ្មានការព្រមព្រៀងរវាងភាគី។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ១០០/០៧-ហូយៀ ខេមបូឌា និងលេខ ៦៤/០៩-ស៊ីណូមេក ២)*

យ៉ាងណាមិញ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ ០៩៦/១៦-តាក សាន់ អេនធើប្រាយ (ខេមបូឌា) ខូអិលធីឌី ត្រង់ហេតុផលនៃចំណុចវិវាទទី១០ យល់ឃើញថា ការបញ្ចប់កិច្ចសន្យាការងាររបស់កម្មករនិយោជិតមុនថ្ងៃផុតកំណត់នៃកិច្ចសន្យាការងាររបស់ពួកគាត់ដោយឯកតោភាគីរបស់និយោជក គឺស្ថិតនៅក្នុងរូបភាពនៃការបញ្ឈប់ពីការងារ ។ *(សូមមើលបន្ថែមសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ២២៣/១៦-យូនីកតា ថេកណូឡូជី (ខេមបូឌា) ហេតុផលនៃចំណុចវិវាទទី១)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របតាមការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ ខាងលើដែរ ។

ចំពោះករណីកម្មករនិយោជិត ហួន សុវីត ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា កាលកំណត់នៃកិច្ចសន្យាការងារដែលមានកំណត់ថិរវេលារបស់គាត់ត្រូវផុតរលត់ នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨ ដែលត្រូវនឹងថ្ងៃច័ន្ទ។ ដោយឡែក និយោជកបានបញ្ចប់កិច្ចសន្យាការងាររបស់គាត់ នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៨ ដែលជាថ្ងៃសៅរ៍ ពោលគឺនៅមុនកិច្ចសន្យាការងារមានកំណត់ថិរវេលារបស់គាត់ដល់កាលកំណត់។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ករណីនេះ គឺជាការបញ្ឈប់កម្មករនិយោជិត ហួន សុវីត ពីការងារ មុនពេលកិច្ចសន្យាការងារដែលមានកំណត់ថិរវេលារបស់គាត់ដល់កាលកំណត់ បើទោះបីជា និយោជកបានជូនដំណឹងមុនស្តីពីការមិនបន្តកិច្ចសន្យាការងារ និងបានគិតប្រាក់ឈ្នួលរបស់កម្មករនិយោជិត រហូតដល់ថ្ងៃដែលកិច្ចសន្យាការងាររបស់គាត់ដល់កាលកំណត់ក៏ដោយ ។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិត ហួន សុវីត ត្រូវបានទទួលរងការបញ្ឈប់ពីការងារ គឺមិនមែនជាការមិនបន្តកិច្ចសន្យាការងារដែលមានកំណត់ថិរវេលានោះឡើយ ។

**ជាបន្ត ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើកម្មករនិយោជិត ហួន សុវីត ជាកម្មករនិយោជិត ដែលអាចទទួលបានការការពារពិសេសពីការបញ្ឈប់ពីការងារដែរ ឬទេ ?**

កថាខណ្ឌទី១ មាត្រា ៤៣ នៃច្បាប់ស្តីពីសហជីព ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ បានចែងថា ៖ “*រាល់ការបញ្ឈប់ប្រតិភូបុគ្គលិក ឬរាល់ការបញ្ឈប់បេក្ខជនណាម្នាក់ពីការងាររបស់ខ្លួនអាចធ្វើទៅបានលុះត្រាតែមានការយល់ព្រមពីអធិការការងារ ។...*” ។

មាត្រា ៦៧ នៃច្បាប់ស្តីពីសហជីព ដដែល ចែងថា ៖ “*កម្មករនិយោជិតទាំងអស់ ដែលជាបេក្ខជនឈរឈ្មោះសម្រាប់ការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំគ្រប់គ្រងសហជីព ទទួលបាននូវការការពារពីការរងគ្រោះ និងការបញ្ឈប់ពីការងារដូចប្រតិភូបុគ្គលិកដែរ ។ ការការពារនេះមានរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃ មុនការ បោះឆ្នោតហើយត្រូវបញ្ចប់ក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃ ក្រោយការបោះឆ្នោត ប្រសិនបើបេក្ខជនទាំងនេះមិនបានជាប់ឆ្នោត ។ ដើម្បីទទួលបានការការពារពិសេសនេះ សហជីពត្រូវជូនដំណឹងទៅនិយោជក និងចម្លងជូនក្រសួងទទួលបន្ទុកវិស័យការងារ អំពីបេក្ខភាពនេះ តាមគ្រប់មធ្យោបាយទាំងអស់ ដែលទុកជាបានការ ។*

*ចាប់តាំងពីពេលដាក់ពាក្យសុំចុះបញ្ជីសហជីពទាំងអស់ដែលជាស្ថាបនិក ឬកម្មករនិយោជិតដែលស្ម័គ្រចិត្តចូលជាសមាជិកសហជីពនេះ ក្នុងពេលកំពុងស្នើសុំចុះបញ្ជីត្រូវទទួលបានការការពារដូចគ្នានឹងប្រតិភូបុគ្គលិកដែរ ។ ការការពារនេះមានរយៈពេលរហូតដល់ ៣០ (សាមសិប) ថ្ងៃ ក្រោយកាលបរិច្ឆេទដែលក្រសួងទទួលបន្ទុកវិស័យការងារបញ្ជាក់អំពីបញ្ជិកាសហជីព...*” ។

យោងតាមសំណុំរឿងលេខ ១៦៩/១៦-ម៉នីង គួរី ហ្គាមេន អ៊ីនធើប្រាយ ខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី១ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយថា ៖ “*យោងតាមមាត្រា ៦៧ នៃច្បាប់ស្តីពីសហជីព ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ដើម្បីទទួលបានការការពារពិសេសពីការបញ្ឈប់ពីការងារ កម្មករនិយោជិតត្រូវបំពេញលក្ខខណ្ឌ ចំនួន ០៣ គឺ* ***លក្ខខណ្ឌទី១*** *៖ កម្មករនិយោជិត គឺជាកម្មករនិយោជិតដែលទទួលបាននូវការការពារពិសេស,* ***លក្ខខណ្ឌទី២*** *៖ ការបញ្ឈប់ពីការងារស្ថិតនៅក្នុងពេលដែលពួកគេបានទទួលនូវការការពារ (រយៈពេល ៤៥ ថ្ងៃមុនថ្ងៃបោះឆ្នោតសហជីព និងត្រូវបញ្ចប់ក្នុងរយៈពេល ៤៥ ថ្ងៃ ក្រោយថ្ងៃបោះឆ្នោតសហជីព) និង* ***លក្ខខណ្ឌទី៣*** *៖ កម្មករនិយោជិតត្រូវជូនដំណឹងដល់និយោជក និងចម្លងទៅក្រសួងទទួលបន្ទុកវិស័យការងារ អំពីឈ្មោះអ្នកដែលត្រូវទទួលការការពារតាមគ្រប់មធ្យោបាយ ដែលទុកជាបានការ ។*” ។ *(សូមមើលបន្ថែមសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១៧០/១៦-ចាយូ (ខេមបូឌា) អ៊ីមភែរីល មេនូហ្វេកឆឺរីង ខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី១ និងលេខ ១៨៨/១៦-ប្រ៊ីន សាំមីត (ខេមបូឌា) លីមីធីត ហេតុផលនៃចំណុចវិវាទទី២)*

ពាក់ព័ន្ធនឹងការចម្លងជូនទៅក្រសួងទទួលបន្ទុកវិស័យការងារនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងលេខ ១៦៩/១៦-ម៉នីង គួរី ហ្គាមេន អ៊ីនធើប្រាយ ខូអិលធីឌី ត្រង់ហេតុផលនៃចំណុចវិវាទទី១ ដដែល បានបកស្រាយថា៖ “*ការចម្លងជូនដែលមានចែងនៅក្នុងមាត្រា ៦៧ នៃច្បាប់ស្តីពីសហជីពនេះ មិនគួរចាត់ទុកជាកាតព្វកិច្ចបន្ថែម សម្រាប់កម្មករនិយោជិតទេ នៅក្នុងករណីដែលកម្មករនិយោជិតបានជូនដំណឹងទៅនិយោជក តាមគ្រប់មធ្យោបាយ ដែលទុកជាបានការ រួចហើយ ។ បន្ថែមពីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ថា គោលបំណងនៃមាត្រានេះ គឺមិនមានបំណងបង្កើតឧបសគ្គក្នុងការអនុវត្តសិទ្ធិបង្កើតសហជីព ដែលធានាដោយរដ្ឋធម្មនុញ្ញ និងសន្ធិសញ្ញាអន្តរ*

*ជាតិ ស្តីពីសិទ្ធិមនុស្ស និងអនុសញ្ញាស្នូលនៃអង្គការអន្តរជាតិខាងការងារ ដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័នឡើយ ប៉ុន្តែ វាជាការសម្រួលដល់ការអនុវត្តសិទ្ធិសហជីពនេះទៅវិញទេ ក្នុងករណីដែលមានការជំទាស់ ពីនិយោជក ។" ។*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ ក៏យល់ស្របទទួលយកហេតុផល និងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងសំណុំរឿងទាំងពីរខាងលើដែរ ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើកម្មករនិយោជិត ហួន សុវីត បានបំពេញគ្រប់លក្ខខណ្ឌទាំង ៣ ខាងលើនេះ ដែរ ឬទេ?

**លក្ខខណ្ឌទី១ ៖ កម្មករនិយោជិតជាប្រភេទកម្មករនិយោជិតដែលទទួលបានការការពារ**

យោងតាមលិខិតរបស់កម្មករនិយោជិតដែលមានកម្មវត្ថុ ៖ ជូនដំណឹងអំពីសមាសភាពថ្នាក់ដឹកនាំ និងសមាជិកគណៈកម្មាធិការសហជីពចលនាកម្មករប្រចាំរោងចក្រកាត់ដេរ ប្រេស៊ីច ហ្គាមេន ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៨ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា សហជីពចលនាកម្មករប្រចាំរោងចក្រកាត់ដេរ ប្រេស៊ីច ហ្គាមេន គឺបានរៀបចំការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីព នៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៨ ដោយមានបេក្ខជនជាប់ឆ្នោតជាថ្នាក់ដឹកនាំសហជីព ចំនួន ៣ នាក់ ក្នុងនោះរួមមានឈ្មោះ ហួន សុវីត ជាប់ជាប្រធានសហជីពផងដែរ ។ ហេតុនេះ យោងតាមមាត្រា ៦៧ នៃច្បាប់ស្តីពីសហជីពខាងលើ កម្មករនិយោជិត ហួន សុវីត ជាប្រភេទកម្មករនិយោជិតដែលទទួលបានការការពារពីការបញ្ឈប់ពីការងារ ។ ដូចនេះ លក្ខខណ្ឌទី១ ត្រូវបានបំពេញ ។

**លក្ខខណ្ឌទី២ ៖ ការបញ្ឈប់ពីការងារស្ថិតនៅក្នុងពេលដែលកម្មករនិយោជិតបានទទួលនូវការការពារ**

នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៨ ភាគីកម្មករនិយោជិតបានយកលិខិតជូនដំណឹងអំពីសមាសភាពថ្នាក់ដឹកនាំ និងសមាជិកគណៈកម្មាធិការសហជីពចលនាកម្មករប្រចាំរោងចក្រកាត់ដេរ ប្រេស៊ីច ហ្គាមេន ទៅឱ្យឈ្មោះ សៅ សុគន្ធា ប៉ុន្តែ គាត់បដិសេធមិនទទួលយកលិខិតជូនដំណឹងរបស់សហជីពឡើយ ។ នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨ ភាគីកម្មករនិយោជិតដាក់លិខិតជូនដំណឹងអំពីសមាភាពថ្នាក់ដឹកនាំ និងសមាជិកគណៈកម្មាធិការសហជីពចលនាកម្មករប្រចាំរោងចក្រ ប្រេស៊ីច ហ្គាម៉ិន ទៅប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល ដោយមានហត្ថលេខាទទួលពីឈ្មោះ លឹម ចំណាន ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨ ។ ចំណែក នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨ ភាគីកម្មករនិយោជិតបានដាក់ពាក្យសុំចុះបញ្ជីការសហជីព ទៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល (យោងតាមបង្កាន់ដៃទទួលពាក្យស្នើសុំចុះបញ្ជីរបស់មន្ទីរការងារ ខេត្តកណ្តាល ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨) ។ ជាក់ស្តែងករណីនេះ ភាគីនិយោជកបានបញ្ចប់កិច្ចសន្យាការងាររបស់កម្មករនិយោជិត ហួន សុវីត នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ ២០១៨ ហេតុនេះ យោងតាមការបកស្រាយលើមាត្រា ៦៧ នៃច្បាប់ស្តីពីសហជីពខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកបានបញ្ឈប់កម្មករនិយោជិត ហួន សុវីត នៅក្នុងរយៈពេលដែលគាត់ត្រូវទទួលបានការការពារពិសេស ពោលគឺនៅក្នុងអំឡុងពេលស្នើសុំបញ្ជិកាសហជីព ។ ដូចនេះ លក្ខខណ្ឌទី២ ក៏ត្រូវបានបំពេញដែរ ។

**លក្ខខណ្ឌទី៣ ៖ កម្មករនិយោជិតបានជូនដំណឹងដល់និយោជក និងចម្លងជូនទៅក្រសួងទទួលបន្ទុកវិស័យការងារ អំពីឈ្មោះកម្មករនិយោជិត ដែលត្រូវទទួលបានការការពារតាមគ្រប់មធ្យោបាយ ដែលទុកជាបានការ**

THE ARBITRATION COUNCIL

យោងតាមអង្គហេតុ ភាគីកម្មករនិយោជិតបានលើកឡើងថា នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៨ ភាគីកម្មករនិយោជិតបានយកលិខិតជូនដំណឹងអំពីសមាសភាពថ្នាក់ដឹកនាំ និងសមាជិកគណៈកម្មាធិការសហជីពចលនាកម្មករប្រចាំរោងចក្រកាត់ដេរ ប្រេស៊ីច ហ្គាមេន ទៅឱ្យឈ្មោះ សៅ សុគន្ធា ប៉ុន្តែ គាត់បដិសេធមិនទទួលយកលិខិតជូនដំណឹងរបស់សហជីពឡើយ។ នៅពេលដែលកម្មករនិយោជិតយកលិខិតទៅជូនរដ្ឋបាលនោះ គឺមានវត្តមានរបស់លោក កូ ឆេងសិន ដែលជាប្រធានរដ្ឋបាល (ដែលបានចូលរួមក្នុងសវនាការអាជ្ញាកណ្តាលនេះដែរ)។ ករណីនេះ នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា តំណាងភាគីនិយោជក ដែលមានឈ្មោះ កូ ឆេងសិន ដែលជាប្រធានរដ្ឋបាល ដែលបានចូលរួមក្នុងសវនការអាជ្ញាកណ្តាលនេះដែរ ក៏ទទួលស្គាល់ដែរថា កម្មករនិយោជិត ហួន សុវីត បានយកលិខិតទៅឱ្យឈ្មោះ សៅ សុគន្ធា ប៉ុន្តែ គាត់មិនបានដឹងថា លិខិតនោះជាលិខិតអ្វីនោះទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសន្និដ្ឋានបានថា ភាគីកម្មករនិយោជិតពិតជាបានជូនដំណឹងទៅនិយោជក អំពីឈ្មោះកម្មករនិយោជិតដែលទទួលបានការការពារ ទៅភាគីនិយោជករួចហើយ។

ជាងនេះទៅទៀត នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨ ភាគីកម្មករនិយោជិតដាក់លិខិតជូនដំណឹងអំពីសមាភាពថ្នាក់ដឹកនាំ និងសមាជិកគណៈកម្មាធិការសហជីពចលនាកម្មករប្រចាំរោងចក្រ ប្រេស៊ីច ហ្គាម៉ិន ទៅប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល ដោយមានហត្ថលេខាទទួលពីឈ្មោះ លឹម ចំណាន ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨ រួចហើយដែរ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីកម្មករនិយោជិតបានបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការជូនដំណឹងទៅនិយោជក និងចម្លងជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ពីឈ្មោះកម្មករនិយោជិតដែលទទួលបានការការពារតាមគ្រប់មធ្យោបាយ ដែលទុកជាបានការ ស្របតាមមាត្រា ៦៧ នៃច្បាប់ស្តីពីសហជីព រួចហើយ។ ដូចនេះ លក្ខខណ្ឌទី៣ ក៏ត្រូវបានបំពេញដែរ។

យោងតាមការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា កម្មករនិយោជិត ហួន សុវីត បានបំពេញនូវលក្ខខណ្ឌទាំង៣ ដើម្បីទទួលបានការការពារពិសេសហើយ។ ហេតុនេះ កម្មករនិយោជិត ហួន សុវីត គឺជាកម្មករនិយោជិតដែលទទួលបានការការពារពិសេសពីការបញ្ឈប់ពីការងារ។

**តើនិយោជកបានបញ្ឈប់កម្មករនិយោជិត ហួន សុវីត ត្រឹមត្រូវតាមនីតិវិធី ដែលមានចែងនៅក្នុងច្បាប់ស្តីពីសហជីពដែរ ឬទេ?**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ដោយសារផ្អែកតាមការបកស្រាយខាងលើ កម្មករនិយោជិត ហួន សុវីត គឺជាកម្មករនិយោជិតដែលទទួលបានការការពារពីការបញ្ឈប់ពីការងារ។ ហេតុនេះ និយោជកមានកាតព្វកិច្ចក្នុងការស្នើសុំការអនុញ្ញាតពីអធិការការងារជាមុន មុននឹងបញ្ឈប់កម្មករនិយោជិត ហួន សុវីត ពីការងារ ឱ្យស្របតាមមាត្រា ៤៣ និងមាត្រា ៦៧ នៃ ច្បាប់ស្តីពីសហជីពខាងលើ។

យ៉ាងណាមិញ តាមរយៈអង្គហេតុខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកមិនឃើញថា និយោជកបានសុំការអនុញ្ញាតពីអធិការការងារ មុននឹងបញ្ឈប់កម្មករនិយោជិត ហួន សុវីត ពីការងារឡើយ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការបញ្ឈប់កម្មករនិយោជិត ហួន សុវីត ពីការងារ ត្រូវបានធ្វើឡើងដោយមិនមានការ

THE ARBITRATION COUNCIL

អនុញ្ញាតពីអធិការការងារនោះទេ ពោលគឺ មិនត្រឹមត្រូវតាមមាត្រា ៤៣ និងមាត្រា ៦៧ នៃច្បាប់ស្តីពីសហជីព ឡើយ។

លើសពីនេះ ប្រការ ៣៤ នៃប្រកាស ០៩៩ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា ៖ *"...ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានសិទ្ធិ និងអំណាចក្នុងការសម្រេចឱ្យភាគីវិវាទផ្តល់នូវសំណងរដ្ឋប្បវេណី ឬសំណង ខូចខាត ដែលមានលក្ខណៈត្រឹមត្រូវ និងយុត្តិធម៌ ដោយរួមទាំងការ ៖*

*ក. បញ្ជាឱ្យទទួលយកកម្មករនិយោជិត ដែលបានបណ្តេញចេញ ឱ្យចូលមកធ្វើការវិញ នៅតំណែងចាស់ ឬ តំណែងសមរម្យណាមួយ...*

*ខ. បញ្ជាឱ្យបង់ប្រាក់ជាបន្ទាន់នូវប្រាក់ដែលត្រូវបង់..."*។

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបង្គាប់ឱ្យនិយោជកទទួលយកកម្មករ និយោជិត ដែលទទួលបានការការពារចំពោះការបញ្ឈប់ពីការងារឱ្យចូលធ្វើការវិញ នៅពេលនិយោជកមិនបានសុំការ អនុញ្ញាតពីអធិការការងារ។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ១៦៩/១៦-ម៉ានីង គូរី ហ្គាមេន អ៊ីនធើ ប្រាយ ខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី១, លេខ ១៨១/១៦-អ៊ូ ធុង អភិវឌ្ឍន៍កម្ពុជា ខូ អិលធីឌី ហេតុផលនៃចំ ណុចវិវាទទី១, លេខ ២២៩/១៦-អ៊ូ ធុង អភិវឌ្ឍន៍កម្ពុជា ខូអិលធីឌី និង លេខ ០០១/១៧-ដាយអឺម៉ុន ស៊ីធី ប្រាយវេត លីមីធីត ខមភេនី ហេតុផលនៃចំណុចវិវាទទី១)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របទទួលយកហេតុផល និងការបកស្រាយរបស់ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗដែរ។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បង្គាប់ឱ្យនិយោជកទទួលយកកម្មករនិយោជិត ហួន ស៊ីវត ឱ្យចូលធ្វើការនៅកន្លែងដើមវិញ។

យោងតាមអង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច ចេញសេចក្តីបង្គាប់ ដូចតទៅ ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី ១ ៖**

- បង្គាប់ឱ្យនិយោជកទទួលយកកម្មករនិយោជិត ហួន ស៊ីវត ឱ្យចូលធ្វើការនៅកន្លែងដើមវិញ។

**ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ ចំនួន ០៨ ថ្ងៃ បើសិនជាមិន មានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាម រយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងរយៈពេលនេះទេ។*

ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **គល់ ទន្សុនា**

ហត្ថលេខា ៖ ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **អន ណាន**

ហត្ថលេខា ៖ ------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ម៉ែន ម៉ុនឈា**

ហត្ថលេខា ៖ ------------------------------